ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ: [illegible] ប.ស្ថ

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១៥

# សេចក្ដីប្រកាសព័ត៌មាន

## លទ្ធផលនៃការពិនិត្យ និងវាយតម្លៃលើក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ៩ នៅក្នុងខេត្តកំពង់ធំក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន

ក្រសួងបរិស្ថានមានកិត្តិយសសូមជម្រាបជូនដល់សាធារណជនឱ្យបានជ្រាបថា យោងតាមលិខិតលេខ ១០២២ស.ជ.ណ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចកាត់បន្ថយរយៈពេលវិនិយោគមកត្រឹម៥០ឆ្នាំ សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនចំនួន ៩ បន្ថែមទៀត មានផ្ទៃដីសរុប ២១៨៣៩ ហិកតា ដែលស្ថិតក្នុងតំបន់ប្រើប្រាស់ ដោយចីរភាពនៃដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រខេត្តកំពង់ធំ ក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។ រហូតមកដល់ពេលនេះ មានគម្រោងវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនចំនួន ៣៧ ហើយ ដែលត្រូវបានរាជរដ្ឋាភិបាលសម្រេចកាត់បន្ថយរយៈពេលវិនិយោគមកត្រឹម៥០ឆ្នាំ។

ក្រសួងបរិស្ថានសូមជម្រាបជូនផងដែរថា រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់គោលការណ៍សម្រាប់គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចដល់ក្រុមហ៊ុនចំនួន ១១៣ ដែលមានផ្ទៃដីសរុប ៦១០២៩៦,៧៥ ហិកតា ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។ ដើម្បីគ្រប់គ្រងគម្រោងវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចឱ្យមានប្រសិទ្ធភាពខ្ពស់ សំដៅផ្ដល់ភាពកក់ក្ដៅដល់អ្នកវិនិយោគទុន ក៏ដូចជាដោះស្រាយលើផលប៉ះពាល់ទាំងឡាយឱ្យបានត្រឹមត្រូវ ក្រសួងបរិស្ថានបានពិនិត្យនិងវាយតម្លៃគម្រោងវិនិយោគអភិវឌ្ឍន៍ទាំង ១១៣ ដែលក្នុងនោះគម្រោងចំនួន ១០៩ ត្រូវបានដាក់ឆ្លងអង្គប្រជុំគណៈកម្មាធិការអន្តរក្រសួងដើម្បីពិភាក្សា និងលើកសំណើជូន ប្រមុខរាជរដ្ឋាភិបាលក្នុងការពិនិត្យនិងសម្រេច។ ជាលទ្ធផល គម្រោងរបស់ក្រុមហ៊ុនចំនួន២៣ (ផ្ទៃដីសរុប ៩០៦៨២ ហិកតា) ត្រូវបានរាជរដ្ឋាភិបាលសម្រេចនិរាករណ៍(ដកហូត)សិទ្ធិវិនិយោគ គម្រោងចំនួន៤ (ផ្ទៃដីសរុប ៣២២៨៧ហិកតា) ត្រូវបានក្រុមហ៊ុនប្រគល់ដោយស្ម័គ្រចិត្តឱ្យរាជរដ្ឋាភិបាលគ្រប់គ្រងវិញ គម្រោងចំនួន ៤ (ផ្ទៃដីសរុប ១៥៧៩៩ ហិកតា) ត្រូវបានរាជរដ្ឋាភិបាលកាត់បន្ថយទំហំផ្ទៃដីវិនិយោគ និងគម្រោងចំនួន ២០ (ផ្ទៃដីសរុប ១៣១៧១៧,៧៥ ហិកតា) ត្រូវបានរាជរដ្ឋាភិបាលទុកពេលឱ្យពី៦ខែ ទៅ១ឆ្នាំ ដើម្បីបន្តនីតិវិធី (ស្ថិតក្រោមការតាមដាន) ហើយគម្រោងចំនួន ៣៧ (ផ្ទៃដីសរុប ១៧៣៧៣០ ហិកតា) ត្រូវបានរាជរដ្ឋាភិបាលសម្រេចឱ្យបន្តអនុវត្តគម្រោងលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច ដោយកាត់ បន្ថយរយៈពេលនៃកិច្ចសន្យាមកត្រឹម៥០ឆ្នាំ។

រហូតមកដល់ពេលនេះ នៅសល់គម្រោងតែចំនួន ៤ ទៀតប៉ុណ្ណោះ ដែលនឹងត្រូវដាក់ឆ្លងប្រជុំគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យវាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ខាងមុខនេះ ដើម្បីបញ្ចប់ទាំងស្រុងនូវការត្រួតពិនិត្យ និងវាយតម្លៃគម្រោងវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច។ ៤

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖* *ឯកឧត្តម **ស្រ៊ុន ដារិទ្ធិ** នាយខុទ្ទកាល័យក្រសួងបរិស្ថាន*
*ទូរស័ព្ទ៖ ០១២ ៨៤៨ ៨៤៤ ឬអ៊ីម៉ែល៖* srundarith@gmail.com